រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ០៤៥/១៥ អ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០១៥

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១៥
## និងទិសដៅការងារ ខែឧសភា ឆ្នាំ២០១៥
(ពីថ្ងៃទី ២៦/៣/២០១៥ - ២៥/៤/២០១៥)

ក្នុងគោលដៅចូលរួមចំណែកអនុវត្ត " គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព " របស់រាជរដ្ឋាភិបាល ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពីខែមីនា ឆ្នាំ ២០១៥ កន្លងទៅ សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

នៅក្នុងខែមេសាឆ្នាំ២០១៥នេះ មានការបង្ក្រាបបទល្មើសគ្រឿងញៀនដែលបានប្រតិបត្តិការដោយ មន្ទីរប្រឆាំងគ្រឿងញៀន និងបណ្តាស្នងការដ្ឋាននគរបាល បញ្ជាការដ្ឋានកងរាជអាវុធហត្ថ រាជធានី ខេត្ត ចំនួន ២២ គឺ រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កោះកុង, ពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, ព្រះវិហារ, ស្ទឹងត្រែង, រតនគិរី, មណ្ឌលគិរី, ក្រចេះ, ស្វាយរៀង, ព្រៃវែង, តាកែវ, ត្បូងឃ្មុំ, កណ្តាល, កំពត, កំពង់ស្ពឺ, កំពង់ចាម, កំពង់ឆ្នាំង, កំពង់ធំ និងខេត្តសៀមរាប ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបដោយសមត្ថកិច្ចអនុវត្តន៍ច្បាប់ខាងលើ មានបទល្មើសគ្រឿងញៀន៦ករណីធំៗ ដែលបង្ក្រាបដោយកម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀន សហការជាមួយមន្ត្រីនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, នគរបាលរាជធានីភ្នំពេញ, ខេត្តសៀមរាប, ព្រះវិហារ, ក្រចេះ និងខេត្តស្ទឹងត្រែង ដោយបានចាប់យកមេតំហ្វេតាមីន ICE ១.៣៥៧,០៦ ក្រាម, មេតំហ្វេតាមីន WY ៨៦៩,៩៤ ក្រាម និង កូកាអ៊ីន ៥ គ.ក្រ ២៥០ ក្រាម និងឃាត់ខ្លួនជនសង្ស័យ១៥នាក់ ក្នុងនោះមានជនជាតិវៀតណាម ១ នាក់ និងជនជាតិឡាវ ២ នាក់ ។

បញ្ហាគួរកត់សម្គាល់គឺ នៅក្នុងខែមេសានេះ មានការដឹកជញ្ជូនគ្រឿងញៀន កូកាអ៊ីន ១ លើក ឆ្លងកាត់ច្រកអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប (១៦/៤/២០១៥) ដែលធ្វើសកម្មភាពដោយជនជាតិវៀតណាម (លាក់បង្កប់ក្នុងឧបករណ៍ភ្លេង Piano) នាំពីប្រទេសកូឡុំប៊ី ឆ្លងកាត់ប្រទេសប្រេស៊ីល ទីក្រុងដូហា (ប្រទេសកាតា) និងម៉ាឡេស៊ី តាមជើងហោះហើរត្រង់ (ម៉ាឡេស៊ី-សៀមរាប) ក្នុងគោលដៅនាំទៅកាន់ប្រទេសទីបី ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone. Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website : www.nacd.gov.kh

## II. អំពីការងារដឹកនាំ

### ១. ការងារដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

រាជរដ្ឋាភិបាល ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខ បានបន្តណែនាំ និងដឹកនាំនូវគោលការណ៍សំខាន់ៗ ក្នុងសកម្មភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចេញអនុក្រឹត្យ លេខ ៤៩ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

### ២. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តដឹកនាំ និងណែនាំលើការងារជាគោលសំខាន់ៗ មានដូចជា ៖

- ដឹកនាំប្រតិភូជាន់ខ្ពស់ ទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីពង្រឹងចំណងសាមគ្គីភាព និងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីលើការងារត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន កម្ពុជា-ឡាវ
- ជំរុញក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន)
- ផលិតឯកសារផ្សព្វផ្សាយអប់រំ ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន
- ពង្រឹងសមត្ថភាព និងកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប និងព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ពង្រីកកម្មវិធីព្យាបាលដោយផ្អែកលើសហគមន៍ ដោយរៀបចំជាយន្តការដាក់លាក់តាមខ្លឹមសារបីគឺ ការព្យាបាល ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើសមាហរណកម្ម
- បន្តការរៀបចំស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ និងជំរុញកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅរាជធានីភ្នំពេញឱ្យបានឆាប់រហ័ស
- រៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការនិងតុលាការ ពិសេសនៅរាជធានីភ្នំពេញពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីកម្មវិធីផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព និងកម្មវិធីម្ជុល/ស៊ីរ៉ាំងនៅកម្ពុជា
- ធ្វើសម្រង់បទល្មើសនានា ដែលកើតឡើងដោយសាការប្រើប្រាស់គ្រឿងញៀន និងបទល្មើសគ្រឿងញៀន ដោយបញ្ជាក់ពីមុខរបរជនល្មើសឱ្យបានច្បាស់លាស់
- ធ្វើសម្រង់បទល្មើសគ្រឿងញៀនក្នុងដែនសមត្ថកិច្ចតុលាការ
- រៀបចំព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ឱ្យអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៥ ពិសេសដំណើរការព្យាបាលដោយផ្អែកលើសហគមន៍ ដោយពង្រឹងយន្តការគ្រប់គ្រងលើការព្យាបាល បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

ក្នុងខែមេសាឆ្នាំ២០១៥នេះ ៖

- ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុជាតិ វិទ្យុរាជធានី ខេត្ត) ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀន បានបន្តអនុវត្ត ដោយក្រសួង ស្ថាប័នជាសមាជិករបស់អាជ្ញាធរជាតិ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្តនៅទូទាំងប្រទេស តាមកម្មវិធីប្រចាំថ្ងៃ សប្តាហ៍ និងខែ ។
- ការអប់រំផ្សព្វផ្សាយតាមសហគមន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀន ក៏មានការចូលរួមអនុវត្តដោយក្រសួង ស្ថាប័នជាសមាជិករបស់អាជ្ញាធរជាតិ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៤ គឺ ខេត្តក្រចេះ កំពង់ចាម កណ្តាល និងកំពង់ស្ពឺ ដែលលទ្ធផលជារួមមានមហាជនចូលរួមប្រមាណ **១.០៤៤.៣៧៥** នាក់ លើ **២២២.៧១២** នាក់ នៃខែមីនា ឆ្នាំ២០១៥ ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១ ។ ក្នុងនោះ សកម្មភាពដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានចូលរួមអនុវត្តមានដូចខាងក្រោម ៖
  - រៀបចំ និងអញ្ជើញវាគ្មិនក្រសួងព័ត៌មាន, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងធម្មការនិងសាសនា ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុង ៖
    - កម្មវិធីព័ត៌មានពេលថ្ងៃ របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្រោមប្រធានបទស្តីពី ការអប់រំផ្សព្វផ្សាយ ដើម្បីបង្ការបញ្ហាគ្រឿងញៀន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ នៅកម្ពុជា (០៩/៤/២០១៥)
    - កម្មវិធីចក្ខុវិស័យកម្ពុជា របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្រោមប្រធានបទស្តីពី ការអប់រំផ្សព្វផ្សាយដើម្បីបង្ការបញ្ហាគ្រឿងញៀនក្នុងវិស័យសិល្បៈនិងវប្បធម៌ នៅកម្ពុជា (០៩/៤/២០១៥)
    - កម្មវិធីសភាអ៊ីនធឺណែត របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្រោមប្រធានបទស្តីពី ការអប់រំផ្សព្វផ្សាយដើម្បីបង្ការបញ្ហាគ្រឿងញៀនក្នុងវិស័យព្រះពុទ្ធសាសនា នៅកម្ពុជា (០៩/៤/២០១៥)
  - សហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងណែនាំដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត ចូលរួមក្នុងសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ
  - ពិភាក្សាជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីរៀបចំផែនការសកម្មភាពបណ្តុះបណ្តាលដល់ក្រុមជនបង្គោល តាមបណ្តារោងចក្រ សហគ្រាស ស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់ នៃគ្រឿងញៀន និងរៀបចំយន្តការសម្រាប់ការងារអប់រំផ្សព្វផ្សាយនេះ
  - បាននិងកំពុងបន្តកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា ក្រសួងមហាផ្ទៃ ដើម្បីរៀបចំវគ្គផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋានពីបញ្ហាគ្រឿងញៀន
  - សហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់ប្រជាពលរដ្ឋ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស នៅក្នុងស្រុកព្រៃកប្បាស និងស្រុកបាទី មានអ្នកចូលរួម ១.០០០ នាក់ និងនៅវិទ្យាល័យ ហ៊ុនសែន ជម្ពូវ័ន រាជធានីភ្នំពេញ ចំនួន ៤០០ នាក់
  - សហការជាមួយសាកលវិទ្យាល័យជាស៊ីម កំចាយមារ ធ្វើការអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃ

គ្រឿងញៀនដល់និស្សិតឆ្នាំសិក្សាទី១ ចំនួន ១២៨ នាក់

- សហការជាមួយអគ្គនាយកដ្ឋានវិទ្យុ ទូរទស្សន៍ជាតិ និង ឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈកម្មវិធីផ្សព្វផ្សាយពាណិជ្ជកម្ម និងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ នៅខេត្តព្រៃវែង ព្រះសីហនុ សៀមរាប មានមហាជនចូលរួមប្រមាណ ៧៦១.៥០០ នាក់
- បន្តការកែសម្រួលចុងក្រោយលើខ្លឹមសារខិត្តប័ណ្ណអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន, ខិត្តប័ណ្ណផ្សព្វផ្សាយពីការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព (សហការជាមួយក្រសួងសុខាភិបាល), កែសម្រួលចុងក្រោយលើខ្លឹមសារស្ទីកឃ័រ (Sticker) និងសារអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន និងពិភាក្សាជំហានដំបូងក្នុងការកសាងផែនការសកម្មភាពអប់រំជនបង្គោលនៅតាមសណ្ឋាគារ ផ្ទះសំណាក់ និងកន្លែងកម្សាន្តផ្សេងៗទៀត (សហការជាមួយក្រសួងទេសចរណ៍)
- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែមេសា ឆ្នាំ២០១៥ មានអ្នកអានចំនួន **៤១.២៨៦** ដង លើ ៣៣.១៨២ ដង នៃខែមីនា ឆ្នាំ២០១៥ ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

ក្នុងភាពជាដៃគូអនុស្សរណៈនៃយោគយល់គ្នា ជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានចាត់តំណាងចូលរួមក្នុងសិក្ខាសាលារបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីតាមដាន វាយតម្លៃលើផែនការយុទ្ធសាស្ត្រជាតិ លើកទី៤ ឆ្លើយតបទូលំទូលាយនិងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ សំដៅធ្វើយ៉ាងណាឱ្យផែនការយុទ្ធសាស្ត្រនោះ មានសកម្មភាពមួយចំនួនសម្រាប់បង្ការទប់ស្កាត់ការរាលដាលមេរោគអេដស៍ ជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើប៉ាន់គ្រឿងញៀន ។

### ២.២. ការព្យាបាល ស្តារនីតិសម្បទា

- បាននិងកំពុងរៀបចំសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងសមាសភាព របស់គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បាននិងកំពុងបន្តការកែសម្រួលខិត្តប័ណ្ណផ្សព្វផ្សាយពីការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់

- បើកវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ១២ នាក់ (វគ្គ១/ឆ្នាំ២០១៥) ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន តាមប្រព័ន្ធកុំព្យូទ័រ កាលពីថ្ងៃទី០៦-១០ ខែមេសា ឆ្នាំ២០១៥
- បញ្ជូនមន្ត្រីនគរបាល ២០ នាក់ (ខេត្តឧត្តរមានជ័យ ៨ នាក់, ព្រះវិហារ ៥ នាក់, ស្ទឹងត្រែង ៣ នាក់ មន្ទីរប្រឆាំងគ្រឿងញៀន ១ នាក់ និងអគ្គលេខាធិការដ្ឋាន ៣ នាក់) ទៅចូលរួមសិក្ខាសាលានៅខេត្ត

សុរិន ប្រទេសថៃ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា ថៃ កាលពីថ្ងៃទី០៧-១០ ខែមេសា ឆ្នាំ២០១៥

- សហការជាមួយអង្គការ UNODC ចុះត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចប្រតិបត្តិការរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ត្រពាំងផ្លុង ខេត្តត្បូងឃ្មុំ (២០-២២/៤/២០១៥), ត្រពាំងក្រៀល និងអូរស្វាយ ខេត្តស្ទឹងត្រែង (២៣-២៥/៤/២០១៥)

### ៣.២. ការបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀន សរុប **២២៥** ករណី លើ ១៥៩ ករណី នៃខែមីនា ឆ្នាំ២០១៥
- ជនសង្ស័យឃាត់ខ្លួន សរុប ៤៨០ នាក់ (ស្រី ៧៣ នាក់) លើ ៣៣០ នាក់ នៃខែមីនា ឆ្នាំ២០១៥ ក្នុងបទល្មើសគ្រឿងញៀន ២២៥ ករណី និងជនសង្ស័យ ៤៨០ នាក់ ខាងលើគឺ ៖
  - បទល្មើសគ្រឿងញៀនបង្ក្រាបដោយ សមត្ថកិច្ចនគរបាលជាតិ **១៨៧** ករណី, ជនសង្ស័យ **៣៨២** នាក់ (ស្រី ៥៧ នាក់)
  - បទល្មើសគ្រឿងញៀនបង្ក្រាបដោយ សមត្ថកិច្ចកងរាជអាវុធហត្ថ **៣៨** ករណី, ជនសង្ស័យ **៩៨** នាក់ (ស្រី ១៦ នាក់)
- ក្នុងចំនួនជនសង្ស័យ ៤៨០ នាក់ ខាងលើមាន ៤ សញ្ជាតិគឺ ខ្មែរ ៤៦៣ នាក់ (ស្រី ៦៨ នាក់), វៀតណាម ១០ នាក់ (ស្រី ៥ នាក់), អង់គ្លេស ៣ នាក់ (ប្រុស), ឡាវ ៤ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ។
- វត្ថុតាងគ្រឿងញៀនចាប់យក មេតំហ្វេតាមីន (WY) ១.០៤១,៥០ ក្រាម មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១.៩៥៨,២៨ ក្រាម ហេរ៉ូអ៊ីន ០,៣១ ក្រាម កូកាអ៊ីន ៥.២៥០ ក្រាម កញ្ឆាក្រៀម ១៨០,១៨ ក្រាម
- ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានចាប់យក ៖ ម៉ូតូ១០៥ គ្រឿង រថយន្ត ៤ គ្រឿង ប្រាក់កម្ពុជា ១១.៥៨៩.៤០០ រៀល ប្រាក់ថៃ ១.១៤០ បាត ប្រាក់អាមេរិក ៩.៤៩២ ដុល្លារ ប្រាក់វៀតណាម ៨.៧៣២.០០០ ដុង ប្រាក់ឡាវ ១៥៤.០០០ គីប (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២)
- ជនសង្ស័យចាប់តាមដីកា មាន ១០ ដីកា = មនុស្ស ១០ នាក់ (ប្រុស) ជនជាតិខ្មែរ
- សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសល្យវិច័យក្នុងខែមេសា ឆ្នាំ២០១៥ សរុប ១១៥ សំណាក = ១១២ ករណី ក្នុងនោះ ៖
  - សំណាកវិជ្ជមានសារធាតុញៀន មាន ១១១ សំណាក = ១០៩ ករណីគឺ
    - មេតំហ្វេតាមីន ICE ១០២ សំណាក = ៨៨,៦៩ %
    - មេតំហ្វេតាមីន WY ០៧ សំណាក = ៦,០៨ % - ហេរ៉ូអ៊ីន ០២ សំណាក = ១,៧៣ %
  - សំណាកអវិជ្ជមានសារធាតុញៀន ០៤ សំណាក = ០៣ ករណី

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

តាមរបាយការណ៍ទិន្នន័យសារធាតុគីមីផ្សំ ដែលផ្តល់ដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានធ្វើការដកស្រង់យកមកបូកសរុបតែទិន្នន័យសារធាតុគីមីផ្សំ ដែលពាក់ព័ន្ធនឹងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន សរុបមានចំនួន **១១៣.៤៥០** គ.ក្រ ក្នុងនោះ សារធាតុគីមីផ្សំ ដែលពាក់ព័ន្ធនឹងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមានបទដ្ឋាន

បច្ចេកទេសឱ្យនាំចូលដោយ ៖

- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ៧.៤៥០ គ.ក្រ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ១០៦.០០០ គ.ក្រ

ក្រៅពីនោះ ក៏នៅមានសារធាតុគីមី ដែលមានអាជ្ញាប័ណ្ណឱ្យនាំចូលដោយក្រសួងសុខាភិបាលក្នុងទម្រង់ជាវត្ថុធាតុដើម និងទម្រង់ជាឱសថដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដូចមានរាយក្នុងតារាងឧបសម្ព័ន្ធទី២

- បាននិងកំពុងបន្តកិច្ចសហការជាមួយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពាក់ព័ន្ធនឹងនីតិវិធីក្នុងការប្រគល់ជូនក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដើម្បីគ្រប់គ្រងបន្តនិងចាត់ចែងតាមសមត្ថកិច្ចនូវសារធាតុគីមី ចំនួន ១៤ មុខ ទម្ងន់ ១៨ តោន ៩០០ គីឡូក្រាម (រងចាំសាលក្រមស្ថាពរ) ពាក់ព័ន្ធការចរាចរការរឹបអូសប្រេងម្រះព្រៅក្នុំកន្លងមក ។
- បានរៀបចំរួចនូវឯកសាររបាយការណ៍សំយោគពាក់ព័ន្ធការចរាចរ ការរឹបអូសប្រេងម្រះព្រៅក្នុំកន្លងមក ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- រៀបចំដំណើរទស្សនកិច្ចជូនប្រតិភូជាន់ខ្ពស់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ អញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីតំណាងសាមគ្គីភាព និងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជាឡាវ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែននៃប្រទេសទាំងពីរ (ថ្ងៃទី២៦-២៨ ខែមេសា ឆ្នាំ២០១៥)
- សហការជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីចាត់បញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលានៅប្រទេសថៃ ចំនួន ១ លើក ពាក់ព័ន្ធនឹងការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- ពិនិត្យឡើងវិញលើអនុស្សរណៈនៃការយោគយល់គ្នា ដែលបានចុះហត្ថលេខាកន្លងមករវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយនគរបាលសហព័ន្ធអូស្ត្រាលីដើម្បីត្រៀមអនុវត្តបន្តរយៈពេល ២ ឆ្នាំទៀត
- ចូលរួមហ្វឹកហ្វឺនស្តីពីនីតិវិធីពហុប្រតិបត្តិការប្រចាំតំបន់ (SOPMOC) កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ នៅទីក្រុងបាងកក
- បន្តអនុវត្តគម្រោង ស្តីពីភាពជាដៃគូនៃមន្ត្រីអនុវត្តន៍ច្បាប់ក្នុងតំបន់ប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន និងគ្រឿងញៀន (PATROL) ដំណាក់កាលទី២ ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បានបំពេញទិន្នន័យសម្រាប់អនុវត្តផែនការសកម្មភាពត្រួតពិនិត្យគ្រឿងញៀន របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទៅក្នុងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០១៦-២០១៨) របស់ក្រសួងមហាផ្ទៃរួចរាល់ជាស្ថាពរ
- បាននិងកំពុងរៀបចំផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ចូលរួមកិច្ចប្រជុំនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិភាក្សាលើការរៀបចំអនុក្រឹត្យស្តីពី ការរៀបចំនិង

ការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ ២០១៥

- បាននឹងកំពុងរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី ការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន
- បានជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ រៀបចំប្រជុំត្រួតពិនិត្យនិងលើកកម្ពស់ប្រសិទ្ធភាពការងារផ្តល់សេវាព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែឧសភា ឆ្នាំ២០១៥

១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

- រៀបចំ និងអញ្ជើញវាគ្មិនជាតំណាងមកពីក្រសួងកិច្ចការនារី, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្នុង ៖
    - កម្មវិធីព័ត៌មានពេលថ្ងៃ ក្រោមប្រធានបទស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមរយៈប្រព័ន្ធធនាគារជាតិ នៅកម្ពុជា
    - កម្មវិធីចក្ខុវិស័យកម្ពុជា ក្រោមប្រធានបទស្តីពីការអប់រំផ្សព្វផ្សាយដើម្បីបង្ការបញ្ហាគ្រឿងញៀន ក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម នៅកម្ពុជា
    - កម្មវិធីសភាអ៊ីនធឺណែត ក្រោមប្រធានបទស្តីពីការអប់រំផ្សព្វផ្សាយដើម្បីបង្ការបញ្ហាគ្រឿងញៀន ក្នុងវិស័យកិច្ចការនារី នៅកម្ពុជា
- បន្តជំរុញក្រសួងអប់រំ យុវជន និងកីឡា រៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន)
- រៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន
- បន្តកិច្ចសហការជាមួយក្រសួងទេសចរណ៍ បោះពុម្ពស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន ការជួញដូរកុមារ និងអាជីវកម្មផ្លូវភេទ និងរៀបចំផែនការសកម្មភាពផ្សព្វផ្សាយនិងបណ្តុះបណ្តាលក្រុមជនបង្គោល
- សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា ក្រសួងមហាផ្ទៃ រៀបចំវគ្គផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋានពីបញ្ហាគ្រឿងញៀន
- ជំរុញក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការងារបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមរោងចក្រ និងសហគ្រាស
- បន្តកិច្ចសហការជាមួយក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្តគោលដៅ និងវិស័យឯកជន បញ្ជ្រាបការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជននានា

២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

- ចូលរួមសន្និសីទអាស៊ាន លើកទី១ ស្តីពីការស្រាវជ្រាវនិងព្យាបាលអ្នកញៀនគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៥-០៨ ខែឧសភា ឆ្នាំ២០១៥
- ចូលរួមវគ្គបណ្តុះបណ្តាលជាលក្ខណៈអន្តរជាតិ នៅប្រទេសថៃ នាថ្ងៃទី១៨-២៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្មថែមទៀត ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹងនិងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខាភាដែលនៅជិត
- ជំរុញក្រសួសុខាភិបាល រៀបចំរបាយការណ៍ស្តីពីលទ្ធផលផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅកម្ពុជា សម្រាប់ធ្វើជាមូលដ្ឋានបន្តការកៀរគរថវិកាជំនួយ
- បន្តការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- រៀបចំបោះពុម្ពស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ
- រៀបចំផលិតខិត្តប័ណ្ណផ្សព្វផ្សាយពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- រៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការនិងតុលាការ ពិសេសនៅរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- ជំរុញក្រសួងសុខាភិបាល គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីពង្រឹងយន្តការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- សហការជាមួយក្រសួងសុខាភិបាល ធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀតពីការអនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំង នៅកម្ពុជា ។

៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

- រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីយោធានៅសាលានាយទាហានសកម្ម (ត្នោតពង), វិទ្យាស្ថានទ័ពជើងគោក (ថ្កុកតាសេក) និងមជ្ឈមណ្ឌលកងទ័ពជើងគោក (ពេជ្រនិល)
- បន្តបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គ២ ឆ្នាំ២០១៥
- បន្តបើកវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន តាមប្រព័ន្ធអេឡិចត្រូនិច (e-Learning)
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ នៅបណ្ឌិត្យសភា ILEA ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ នាថ្ងៃទី២៧ ខែមេសា ដល់ ០៨ ខែឧសភា ឆ្នាំ២០១៥

- ចូលរួមវគ្គបណ្ដុះបណ្ដាលអនុវត្តច្បាប់គ្រឿងញៀនអាស៊ាន + ៣ លើកទី២ ស្ដីពីការប្រឆាំងថ្នាំញៀន ATS និងសារធាតុញៀនផ្សេងទៀត ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១១-១២ ខែឧសភា ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ
- ចូលរួមកិច្ចប្រជុំនៅប្រទេសសឹង្ហបុរី ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋាននៃបណ្ដាប្រទេសអាស៊ាន លើកទី៥ នាថ្ងៃទី១៣-១៤ ខែឧសភា ឆ្នាំ២០១៥
- បន្តកិច្ចសហការជាមួយអង្គការ UNODC ចុះត្រួតពិនិត្យនិងវាយតម្លៃការិយាល័យទំនាក់ទំនងព្រំដែន (BOL) កំពង់ស្រឡៅ ខេត្តព្រះវិហារ, ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ, ដូង ខេត្តបាត់ដំបង, ព្រំ ខេត្តប៉ៃលិន, ចាំយាម ខេត្តកោះកុង, បាវិត ខេត្តស្វាយរៀង, ភ្នំដិន ខេត្តតាកែវ, ក្អមសំណ និងជ្រៃធំ ខេត្តកណ្ដាល
- ត្រៀមរៀបចំពិធីប្រកាសសមាសភាព តួនាទី ភារកិច្ចរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅទូទាំងប្រទេស ។

៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ
- រៀបចំវគ្គបណ្ដុះបណ្ដាលមន្ត្រីអនុវត្តន៍ច្បាប់ ស្ដីពីការគ្រប់គ្រង ត្រួតពិនិត្យការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀន នៅតាមរាជធានី ខេត្ត
- បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្ដីព្រាងប្រកាសស្ដីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម
- សិក្សាស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន

៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន
- ត្រៀមរៀបចំកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន កម្ពុជា-ឡាវ លើកទី១ (កម្ពុជាធ្វើជាម្ចាស់ផ្ទះ)
- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា-ឡាវ លើកទី១ (កម្ពុជាធ្វើជាម្ចាស់ ផ្ទះ)
- ត្រៀមចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-វៀតណាម លើកទី៣ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម
- អនុវត្តកិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្តិការលើការងារអនុវត្តន៍ច្បាប់ និងការត្រួតពិនិត្យគ្រឿងញៀន ដែលបានចុះហត្ថលេខាជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ។

៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា
- ដឹកនាំប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ និងថ្នាក់រដ្ឋមន្ត្រី នៃបណ្ដាប្រទេសហត្ថលេខីលើអនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣ ស្ដីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងហាណូយ ប្រទេសវៀតណាម នាថ្ងៃទី១៩-២០ ខែឧសភា ឆ្នាំ២០១៥
- បន្តកិច្ចសហការជាមួយអង្គការ UNODC ដើម្បីចុះអង្កេត និងស្វែងយល់ពីការអនុវត្តរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគម្រោង PATROL ដំណាក់កាលទី២
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនតាមយន្តការនៃបណ្ដាប្រទេសក្នុងមហាអនុ

តំបន់ទន្លេមេគង្គ ។

៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បន្តការរៀបចំផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បន្តការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តការរៀបចំសមាសភាព នៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរបស់ រាជធានី ខេត្ត
- រៀបចំកម្មវិធីផ្សព្វផ្សាយពីអនុសញ្ញាអន្តរជាតិស្តីពីគ្រឿងញៀន ដល់មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នដែលជាសមាជិករបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍រដ្ឋបាល និងមន្ត្រីអនុវត្តន៍ច្បាប់នានា នៅតាមរាជធានី ខេត្ត
- ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ឆ្នាំ២០១៤ និងទិសដៅការងារ ឆ្នាំ២០១៥ របស់មន្ទីរប្រឆាំងគ្រឿងញៀន ។/.

អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក មាស_វីរិទ្ធ

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣

" ដើម្បីជូនជ្រាប "

- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីមុខការ "

- ឯកសារ